លីកាដូ

ម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

# CADHO

ODIAN LEAGUE FOR THE PROMOTION
EFENSE OF HUMAN RIGHTS

# មនុស្ស និងការបណ្តុះគំនិតសន្តិភាព
# ដល់ នគរបាល




## សំរាប់អ្នកចូលរួម
**FOR PARTICIPANTS**

រៀបចំដោយ
គ្រូអប់រំសិទ្ធិមនុស្សនៃអង្គការលីកាដូ

**Prepared by**
**LICADHO'S TRAINERS**

# កម្មវិធីបំប៉នសិទ្ធិមនុស្សដល់នគរបាលជាតិ

## ១.ចំណុចខ្លាំ :

ដោយហេតុថា [redacted]មានតួនាទីសំខាន់ក្នុងការថែរក្សាសណ្តាប់ធ្នាប់-សន្តិសុខសាធារណៈនិងស្ថេរភាពសង្គមនោះ ដូច្នេះកម្មវិធីនេះរៀបចំឡើង[redacted]បន្ថែមទៀតអំពីសិទ្ធិមនុស្ស ព្រមទាំងចំណេះដឹងថ្មីមួយចំនួនស្តីពីមូលដ្ឋានគ្រឹះក្នុងការកសាងសន្តិភាពជាតិ ។ [redacted] [redacted]របស់នគរបាលឱ្យកាន់តែខ្លាំងក្លាឡើង ក្នុងការរួមចំណែកបង្កើតយុទ្ធសាស្ត្រ ទប់ស្កាត់អំពើរំលោភសិទ្ធិ[redacted] ហើយបញ្ហាទាំងនេះនៅតែរីករាលដាលយ៉ាងធ្ងន់ធ្ងរ និង គំរាមកំហែងដល់សន្តិសុខ និង ជីវភាព[redacted] ព្រមទាំងនគរបាលផងដែររហូតមកដល់ពេលនេះ ។

## ២.[redacted]

[redacted] :

1-[redacted] គឺជាគ្រឹះនាំទៅរកសុភមង្គល ។

2-[redacted] គឺវាជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងតួនាទីរបស់នគរបាល ដើម្បី[redacted] ដោយគោរពសិទ្ធិមនុស្សនិងច្បាប់។

3-[redacted] [redacted]ចិត្តនឹងបង្កើតជា " *ក្រុមជំនួយសហការ* " បន្ថែមលើមុខងាររបស់ខ្លួន សំរាប់ជួយអប់រំសិទ្ធិមនុស្ស បន្តដល់អ្នកជិតខាង និង អនុវត្តតួនាទីជាភ្នាក់ងារកំសួចជាតាមរយៈ " ក្រុមសហការការងារ " ដើម្បីចាត់ការទៅលើការរំលោភសិទ្ធិមនុស្សនានា តាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយសហការជាមួយក្រុមប្រជាពលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលជាដើម ។

## ៣.វិធីបំពេញការងារវគ្គ

កម្មវិធីសិក្សានៃវគ្គនេះទាំងមូល គឺជារបៀបពិភាក្សាផ្តល់យោបល់គ្នាទៅវិញទៅមក ដោយផ្តោតទៅលើការអប់រំចិត្តសន្តិភាព *(មានន័យថា វិធីដោះស្រាយអ្វីក៏ដោយត្រូវយកលើមូលដ្ឋានសន្តិភាព ឬ តាមវិធីអហិង្សា)* និង ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារសិទ្ធិមនុស្ស នៅក្នុងមូលដ្ឋាន ។ ដូច្នេះបានន័យថាវគ្គនេះគឺផ្តល់ឱកាសឱ្យនគរបាល ចូលរួមនិងផ្តល់យោបល់នៅក្នុងក្រុមពិភាក្សារបស់ខ្លួនទៅលើករណីសិក្សាជាច្រើន ថាតើគួររកដំណោះស្រាយបែបណា ដើម្បីដោះនូវការរំលោភសិទ្ធិមនុស្សទាំងនោះឱ្យមានប្រសិទ្ធិភាព ។

★ វគ្គបំប៉ននេះមានរយៈពេល០៣ថ្ងៃ នឹងរំពឹងទុកថា នគរបាលទាំងអស់នឹងបញ្ចេញមតិយ៉ាងផុលផុស និងពេញទំហឹង ដើម្បីរកឱ្យឃើញនូវ[redacted]សំរាប់ការងារ ។

★ [redacted] អ្នកសំរបសំរួលវគ្គនឹងមានរៀបចំល្បែងស្វាងគំនិត យ៉ាងហោចណាស់ក្នុងមួយថ្ងៃឱ្យបានមួយល្បែង ។

★ [redacted] សិក្ខាកាមនឹងត្រូវបានស្នើសុំឱ្យធ្វើការវាយតំលៃទៅលើលទ្ធផលទូទៅរបស់វគ្គទាំងមូល ។

★ [redacted] នឹងមានវគ្គបន្ត (Follow up)ពីរដងទៀតដោយមានគម្លាតពីគ្នា ២ខែម្តង។ វគ្គទាំងនោះគឺមានរយៈពេលតែ១ថ្ងៃ[redacted] ។

# មាតិកា


| មេរៀនទី | ចំណងជើងមេរៀន | ទំព័រ |
|---|---|---|
| ១ | [illegible]<br>[illegible]<br>[illegible] និង អនុវត្តន៍ផ្ទាល់ | ១-៣ |
| [illegible] | [illegible]<br>[illegible]<br>[illegible] | ៤-១២ |
| [illegible] | [illegible]<br>[illegible]<br>[illegible] និង អនុវត្តន៍ផ្ទាល់ | ១៣-១៧ |
| ៤ | [illegible]<br>-មេរៀន:<br>-សំណួរពិភាក្សា និង អនុវត្តន៍ផ្ទាល់ | ១៨-២១ |
| ៥ | *[illegible]<br>-មេរៀន:<br>-សំណួរពិភាក្សា និង អនុវត្តន៍ផ្ទាល់ | ២២-២៦ |
| ៦ | *[illegible]<br>-មេរៀន: និង ការប្រជុំបញ្ចប់ក្រុម<br>-សំណួរពិភាក្សា និង អនុវត្តន៍ផ្ទាល់ | ២៧-៣៥ |
| ៧ | *[illegible]<br>-[illegible]<br>-សំណួរពិភាក្សា និង អនុវត្តន៍ផ្ទាល់ | ៣៦-៤១ |

# ការកសាងសន្តិភាព

~~~*~~~

## I. ឧត្តមគតិនៃការកសាងសន្តិភាព

អ្នកកសាងសន្តិភាពមានន័យថា គឺជាអ្នកនិយមសន្តិភាពប្រកបដោយសុឆន្ទៈ និងជាអ្នកដោះស្រាយទំនាស់ប្រកបដោយសន្តិវិធី និង យុត្តិធម៌ ។

***ឧទាហរណ៍** :

-អ្នកបញ្ឈប់ជម្លោះ

-អ្នកចូលរួមដោះស្រាយទំនាស់ និង មិនបង្កជម្លោះ

-មិនប្រើអំពើហិង្សា និង និយមការផ្សះផ្សា

-ដោះស្រាយទំនាស់ និង ជួយដោយសន្តិវិធី

-សម្រុះសម្រួលដោយអហិង្សា

-មានទំនុកចិត្តខ្លួនឯង ប្រាជ្ញាឈ្លាសវៃ និង មានសីលធម៌ខ្ពស់

-ស្រលាញ់យុត្តិធម៌ គិតពីផលប្រយោជន៍ប្រជាពលរដ្ឋ . សម្បត្តិជាតិ និង ប្រយោជន៍រួម

-តស៊ូព្យាយាម និង មានការអត់ធ្មត់

-មានមេត្តាធម៌ ហ៊ានលះបង់

-ពុំមានការគុំគួន និង មានទស្សនៈទូលាយ......

## II. ករណីសិក្សា :

យុវជនមួយរូប ដោយចរាចរចង្អៀត បានជិះម៉ូតូកៀរអ្នកម៉ូតូឌុបម្នាក់ ធ្វើឱ្យរលាត់ស្បែកគាត់បន្តិចបន្តួច ។ ពេលនោះ យុវជនបានសុំទោសអ្នកម៉ូតូឌុប គាត់មិនព្រមទទួលនូវការសុំទោសពីយុវជននោះឡើយ ហើយបានជេរប្រមាថយុវជននោះ គេមិនបានតបត បន្ទាប់មកក៏ឡើងជិះម៉ូតូចេញទៅ ។ ពេលនោះ អ្នកម៉ូតូឌុប ក៏ឡើងជិះម៉ូតូខ្លួនតាមយុវជននោះកិតពីក្រោយ ហើយបន្តជេរដៀលយុវជននោះតទៅទៀត ដូចជា ដៀលថា អាក្មេងឯងសម័យឥឡូវព្រហើន១ណាស់ ។ យុវជននោះឈប់ម៉ូតូ
~~~

ហើយ[redacted] យុវជនបានហក់ភ្លែតដាល់ចំសៀតផ្កាអ្នកម៉ូតូឌុប ធ្វើឱ្យគាត់ឡើងសឹ បន្ទាប់[redacted]មកចោមរោមវាយ ទាត់ធាក់អ្នកម៉ូតូឌុបនោះបន្ថែមទៀត អ្នកម៉ូតូឌុប បែ[redacted]ឈាម ពេលនោះប៉ូលីសបានមកដល់ ពួកយុវជនទាំងនោះបានគេចខ្លួនយ៉ាង [redacted]

**សំនួរ**

**១.អ្នកណាជាអ្នកបង្កហេតុ ? មកពីហេតុអ្វី ?**

**២.តើដំណោះស្រាយរបស់ភាគីទាំងពីរនាំមកនូវអ្វី ? តើវានាំមកនូវសន្តិភាពឬទេ ? ហេតុអ្វី ?**

៣.តើលទ្ធផលជាក់ស្តែងនៃជម្លោះនេះ បណ្តាលឱ្យយ៉ាងដូចម្តេច ?

៤.អ្នកណាជាអ្នកខុស អ្នកម៉ូតូឌុប ឬ យុវជន ? ហេតុអ្វី ?

៥.តើមានវិធីដូចម្តេចខ្លះ ដើម្បីកុំឱ្យរឿងនោះក្លាយទៅជាមានជម្លោះយ៉ាងដូច្នេះ ?

## III.ពិភាក្សាបន្តនៅលើសំណួរខាងក្រោមនេះ

**១.តើមកពីមូលហេតុអ្វីខ្លះ** ដែលបណ្តាលឱ្យមានជម្លោះកើតឡើងនៅក្នុងសង្គមកម្ពុជា ?

**២.តើមានជម្លោះអ្វីខ្លះ** ដែលបាននិងកំពុងកើតឡើង ?

៣.តើមានជម្លោះអ្វីខ្លះ ជាជម្លោះចម្បងៗដែលបាននិងកំពុងកើតឡើង ?

៤.ដើម្បីធ្វើឱ្យប្រទេសមានសន្តិភាព :

ក/តើសង្គមជាតិ គួររៀបចំកម្មវិធីដូចម្តេចខ្លះ សំរាប់ការកសាងសន្តិភាព ?

ខ/តើនគរបាលត្រូវមានតួនាទីយ៉ាងដូចម្តេច សំរាប់ការកសាងសន្តិភាព ?

គ/តើថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ត្រូវមានតួនាទីយ៉ាងដូចម្តេច សំរាប់ការកសាងសន្តិភាព ?

## IV.សំណួរពិភាក្សាបញ្ចប់

**១.បើសង្គមនាំ**មកនូវសន្តិភាពហើយ តើវានាំមកនូវអ្វីខ្លះ ?

នោះទុកសិន ដើម្បីជៀសវាងការរីករាលដាល ឬ ការផ្ទុះនៃបញ្ហានោះ ។ ចំណែកឯភាពខុសគ្នារវាងខ្មែរយើងនោះ គឺខ្មែរយើងភាគច្រើនខ្លាចការរិះគន់ ខ្លាចការពិត នេះគឺបណ្តាលមកពីជាតិយើងខ្វះការសំរបសំរួល ឬការមិនព្រមធ្វើសម្បទាន (ការសុខចិត្តចែករំលែក) ឱ្យគ្នាទៅវិញទៅមក ព្រមទាំងការខ្វះទទួលខុសត្រូវ និងជំនឿទុកចិត្តរវាងគ្នានឹងគ្នា ។ ដូច្នេះដើម្បីកែលំអនូវការខ្វះខាតទាំងនេះ ជនជាតិខ្មែរគប្បីទទួលយកនូវការផ្លាស់ប្តូរគំនិតពីហិង្សាចិត្តដែលសល់ពីភ្លើងសង្គ្រាមនោះឱ្យទៅជាផ្នត់គំនិតថ្មី ស្អាតស្អំ ពិតត្រង់ និងមិនស្គាល់តែប្រយោជន៍ផ្ទាល់ខ្លួន ។ល។ កត្តាទាំងនេះនឹងនាំមកនូវសន្តិភាពដល់សង្គមជាតិ ។

**២.វិធីបង្ការទំនាស់**

មធ្យោបាយដែលអាចជួយបង្ការទំនាស់មួយផ្នែក គឺខិតខំធ្វើឱ្យរស់ឡើងវិញនូវប្រពៃណីដូនតា ដែលមាននៅក្នុងគ្រួសារ តាមវត្តអារាម ឬតាមភូមិស្ថាន ប្រពៃណីទាំងនោះមានដូចជា ចេះគោរពចាស់ទុំ ចេះមានមេត្រីភាព ចេះមានការយោគយល់ ឬ អធ្យាស្រ័យគ្នា និង គួរតែមានកម្មវិធីអប់រំអំពីសីលធម៌ព្រះពុទ្ធសាសនា ចរិយាធម៌ (ឫកពា.បែបបទ) សុជីវធម៌ (ការចេះប្រមាណការគួរសម) ព្រហ្មវិហារធម៌ (ធម៌ជាលំនៅនៃចិត្តដ៏ប្រសើរ) ដែលអប់រំឱ្យមានគុណធម៌ផ្លូវចិត្ត ដូចជាធ្វើឱ្យមានកិរិយាមារយាទរម្យទម គ្មានចិត្តបង្កជម្លោះ មានតែចិត្តផ្សះផ្សា ចិត្តអធ្យាស្រ័យ មិត្តប៉ាន់ប្រមាណ ។ល។ ចំណុចទាំងអស់នេះធ្វើឱ្យទប់ស្កាត់បាននូវរាល់ទំនាស់ និងជម្លោះបែកបាក់ជាយថាហេតុទាំងឡាយនៅក្នុងសង្គម ។

**៣.គតិបណ្ឌិតខ្មែរ**

គតិបណ្ឌិតខ្មែរក្នុងការបង្ការទំនាស់និងផ្សះផ្សាទំនាស់ ជាអាទិមាន :

1-ហេតុដែលនាំឱ្យមានអំពើអាក្រក់ ដូចជា (ទោសៈ)កំហឹងឆេវឆាវ ក្រេវក្រោធ , (មោហៈ) សេចក្តីវង្វេង និង (លោភៈ) .ការចង់តែបានសំរាប់ខ្លួនមិនគិតពីអ្នកដទៃ ឬសេចក្តីលោភលន់ ។

2-សីលធម៌ព្រះពុទ្ធសាសនា (បញ្ចសីល)

-មិនឱ្យសម្លាប់ (បាណាតិបាតា)

-ហាមលួចប្លន់ ស៊ីសំណូក (អទិន្នាទានា)

-ហាមប៉ះពាល់ កូនប្រពន្ធ-ប្តីគេ ផ្តែកកាម (កាមេ)

-ហាមគ្រឿងស្រវឹង (សុរា)

-មិនកុហក បោកបញ្ឆោត ញុះញង់ និយាយដើមគេ (មុសា)

*3. អគតិបួនយ៉ាង :*

**-ឆន្ទាគតិ : លំអៀងព្រោះស្រលាញ់**

**-ទោសាគតិ : លំអៀងព្រោះក្រោធ ព្រោះស្អប់**

**-ភយាគតិ : លំអៀងព្រោះភ័យ ព្រោះខ្លាច**

-មោហាគតិ : លំអៀងព្រោះវង្វេង

*4. ព្រហ្មវិហារធម៌ :*

-មេត្តា : សេចក្តីស្រលាញ់គ្មានព្រំដែន ប្រាថ្នាចង់ឱ្យអ្នកដទៃបានសេចក្តីសុខ

-ករុណា : សេចក្តីអាណិតអាសូរ

-មុទិតា : សេចក្តីត្រេកអរចំពោះអ្នកដទៃ

-ឧបេក្ខា : ការដាក់ចិត្តជាកណ្តាល

*5. ទំនៀមខ្មែរផ្សេងៗទៀត មាន* : ការបួសរៀនតាមលក្ខណៈព្រះពុទ្ធសាសនា បុណ្យទានផ្សេងៗ មានភ្ជុំបិណ្ឌជាដើម ។ ទំនៀមទាំងអស់នេះសុទ្ធតែជាការអប់រំចិត្តឱ្យល្អ មានសន្តិភាព បានន័យថា ជាផ្លូវជួយតម្រង់មនុស្សឱ្យប្រកាន់តែអំពើល្អ មិនបៀតបៀនអ្នកដទៃ និងមានចិត្តលះបង់ ។ល។

**ចប់** ____


គោរពសិទ្ធិមនុស្ស-ច្បាប់
-គោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស
-មិនប្រើហិង្សា,ទារុណកម្ម,សម្លាប់
អហិង្សា
កត្តាសន្តិភាព
យុត្តិធម៌
-គោរពច្បាប់
ព្រះពុទ្ធសាសនា
-ចងចាំសីល៥
-ប្រកាន់អគតិ
-មានព្រហ្មវិហារ


សន្តិភាព តែ :
ហិង្សា
ផ្តាច់ការ
អយុត្តិធម៌
ពុករលួយ
សង្គ្រាម

# នគរបាល និង អំពើទារុណកម្ម

***********❋***********

## I. ទស្សនៈ

ទស្សនៈសិទ្ធិមនុស្សក៏ដូចជាច្បាប់របស់ប្រទេសកម្ពុជា បានប្រឆាំងយ៉ាងដាច់ខាតអំពើទារុណកម្ម ក៏ប៉ុន្តែ បញ្ហានេះនៅតែកើតមានជាអលជ្ជី ។ ហេតុអ្វី ? ពីព្រោះនៅក្នុងចំណោមនគរបាលគេតែងតែយល់ថា ការវាយដំធ្វើទារុណកម្មទៅលើមនុស្ស វាជាទំនៀមទម្លាប់នៃរបបសង្គមខ្មែរ ឬក៏ការធ្វើទារុណកម្មទៅ លើជនជាប់សង្ស័យ ឬ ជនជាប់ចោទ វាអាចផ្តល់នូវលទ្ធផលជាវិជ្ជមានដល់ពួកគេច្រើនបែបច្រើនយ៉ាង យ៉ាងហោចណាស់ក៏គេគិតថា ការប្រើអំពើគ្រេវគ្រោធ ឬហិង្សាគឺជាវិធីដ៏មានប្រសិទ្ធិភាពចំពោះអ្នកដែល ប្រព្រឹត្តបទល្មើស ជាពិសេសដើម្បីឱ្យគេរាងចាល ។ ក៏ប៉ុន្តែវាអាចជាលេស ឬជាល្បិចផ្សេងៗរបស់នគរបាល ខ្លះ សំរាប់បំរើនូវផលប្រយោជន៍អ្វីមួយដល់ខ្លួនគេ ។ ការធ្វើទារុណកម្ម គឺជាអំពើមួយដ៏ឃោរឃៅ អមនុស្សធម៌ នាំឱ្យបាត់បង់នូវតម្លៃនិងសេចក្តីថ្លៃថ្នូររបស់មនុស្សឬក៏ជាការប្រមាថមើលងាយសិទ្ធិមនុស្ស ពេញទី ដែលទង្វើនេះបង្កើតឱ្យមានការឈឺចាប់ខាងផ្លូវចិត្ត ផ្លូវកាយ និងផ្លូវភេទ ធ្វើឡើងដោយចេតនា ទៅលើបុគ្គលណាម្នាក់ ក្នុងគោលបំណងណាមួយដើម្បីជំរិតយកអ្វីពីបុគ្គលនោះ ។ បច្ចុប្បន្ននេះគេនៅតែ សង្កេតឃើញថា អំពើទារុណកម្មនៅតែកើតមានស្ទើរជាទូទៅតាមរយៈការចាប់ខ្លួនជនសង្ស័យ នៅពេល សួរចម្លើយ ក៏ដូចជានៅតាមមន្ទីរឃុំឃាំងនានា ។ល។ ទោះបីជាមានការអប់រំ និង ផ្សព្វផ្សាយ តាមរយៈរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលយ៉ាងណាក៏ដោយ។ ម្យ៉ាងវិញទៀតបញ្ហានេះ នៅតែ មានការឆ្លើយដាក់គ្នា ឬស្តីបន្ទោសទម្លាក់កំហុសទៅលើសិទ្ធិមនុស្ស ឬភ្នាក់ងារសិទ្ធិមនុស្ស ដោយ អះអាងថា មកពីមានអង្គការសិទ្ធិមនុស្សនេះហើយទើបជនខិលខូចបានដៃ ឬក៏បណ្តាលឱ្យកើតមនុស្ស ខូចកាន់តែច្រើនឡើងៗ ខុសពីពេលណាៗទាំងអស់ ។ល។ ការអនុវត្តន៍នីតិវិធីសួរចម្លើយដោយប្រើ ទារុណកម្ម គឺជាវិធីចាស់គំរិល ហួសសម័យ មិនសមនឹងប្រើនៅក្នុងពិភពលោកបច្ចុប្បន្ននេះឡើយ ក៏ប៉ុន្តែ យើងក៏មិនបដិសេធនូវការគោរពសិទ្ធិមនុស្ស ក៏ដូចជាការគោរពច្បាប់នៅក្នុងចំណោមនគរបាលរបស់យើង កន្លងមក ក្នុងការអនុវត្តន៍នីតិវិធីដ៏ត្រឹមត្រូវនោះដែរ ក៏ប៉ុន្តែអ្វីដែលយើងចង់និយាយឬចង់ពិភាក្សានៅ ពេលនេះ គឺរកឱ្យឃើញនូវចំណុចស្របគ្នាមានលក្ខណៈប្រសើរជាងមុន ដើម្បីឈានទៅបំបាត់អំពើទារុណ កម្មទាំងស្រុង គ្រប់ប្រភេទឱ្យបានជាស្ថាពរ ។

ការធ្វើទារុណកម្ម គឺជាអំពើរំលោភសិទ្ធិមនុស្ស
ដែលត្រូវតែយកទៅផ្តន្ទាទោសតាមច្បាប់



## II.សំនួរពិភាក្សា

**ពិភាក្សាលើកទី១*

១.គួរមានវិធានការដូចម្តេចខ្លះ អំពីប៉ូលីសម្នាក់ដែលតែងតែជេរ វាយទាត់ ធាក់ប្រពន្ធគាត់ ជាពិសេសនៅពេលបើក ប្រាក់ខែម្តងៗ បន្ទាប់ពីគាត់ស៊ីផឹកជាមួយមិត្តភក្តិរបស់គាត់។

២.ពិភាក្សារកហេតុផលថា ត្រូវតែគាំទ្រអំពើទារុណកម្មទៅលើជនជាប់សង្ស័យនិងជនជាប់ចោទ។

៣. ពិភាក្សារកហេតុផលថា មិនត្រូវគាំទ្រអំពើទារុណកម្មទៅលើជនជាប់សង្ស័យនិងជនជាប់ចោទ ។

**ពិភាក្សាលើកទី២*

១.តើអង្គការសិទ្ធិមនុស្សជួយជនខិលខូច ពិត ឬ មិនពិត ? ហេតុអ្វី ?

២.តើអង្គការសិទ្ធិមនុស្សមានអំណាចប៉ុណ្ណាក្នុងតួនាទីរបស់ខ្លួនជុំវិញជនល្មើស ?

៣.តើអស់លោកអ្នកមានវិធានការអ្វីខ្លះ ដើម្បីឈានទៅបំបាត់អំពើទារុណកម្មទាំងស្រុងនោះ?

## III.អត្ថបទជំនួយ

### ១/.ផលវិបាកនៃអំពើទារុណកម្ម

ការធ្វើទារុណកម្ម ខាងផ្លូវចិត្តក្តី ខាងផ្លូវកាយក្តី ការចាប់រំលោភសេពសន្ថវៈក្តី ទៅលើអ្នកណាមួយ អ្នកនោះឈឺចាប់ណាស់ មិនថាគេថាយើងឡើយ។ ហេតុដូច្នេះហើយ បើជនណាបានទទួលនូវទារុណកម្មជននោះទទួលបាននូវផលវិបាកដូចជា : ហើម,ប៉ោង,ជាំខ្មៅ-ក្រហម-ខៀវ,ដាច់សាច់, មានស្នាមរបួស, ហូរឈាម , បាក់, ថ្លោះ,គ្រិច , រយះដាច់,ស្រាំ , រលាក,កន្ទួល និងម៉្យាងទៀត ស្លុតស្មារតី , ព្រួយបារម្ភ, ភ្លេចភ្លាំង ,ចិត្តវិកល វ៉ាវ៉ៃ,បាក់ស្បាត ។ល។ បើសិនជាជនណាម្នាក់ឬច្រើននាក់ទទួលបាននូវលទ្ធផលដូចខាងលើនេះនឹងនាំឱ្យកើតជំងឺភ័យខ្លាច , ជំងឺថប់ អារម្មណ៍ , មានការអៀនខ្មាស ហើយនិងបាត់ការចងចាំ តើអ្នកណាជាអ្នកជួយដោះស្រាយខ្លួនគេនិងគ្រួសារគេ ? ប្រាកដជាលទ្ធផលនឹងធ្វើឱ្យអំពល់ដល់សង្គមជាតិវិញដដែល ។ ដូច្នេះបុគ្គលទាំងឡាយមិនគួរប្រព្រឹត្តអំពើទាំងនេះសំរាប់ជាទីត្រេកត្រអាលឱ្យខ្លួន ហើយធ្វើឱ្យអ្នកដទៃឈឺចុកចាប់នោះឡើយ។

## ២.ច្បាប់ជាតិនិងអន្តរជាតិ ទាក់ទងនឹងអំពើទារុណកម្ម

**ក/ សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស :**

មាត្រា៥ : គ្មានជនណាម្នាក់ត្រូវបង្ខំឱ្យទទួលទារុណកម្ម និងអំពើឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ ។

**ខ/ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :**

**មាត្រា៣៨ ( វាក្យខណ្ឌ៤ក្នុងកថាខណ្ឌ៤) :**

ការបង្ខិតបង្ខំធ្វើបាបលើរូបរាងកាយ ឬ ប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬ ជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។

គ/ អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម : រដ្ឋភាគីត្រូវធានាថា អំពើទារុណកម្មទាំងអស់ គឺជាអំពើផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ។ ចំពោះការប៉ុនប៉ងធ្វើទារុណកម្ម និង អំពើរបស់បុគ្គលណាដែលបានចាត់ទុកជាការសមគំនិត ឬការចូលរួមក្នុងការធ្វើទារុណកម្ម ក៏ត្រូវចាត់ទុកជាអំពើខុសច្បាប់ដែរ ។ រដ្ឋជាភាគីនីមួយៗ ត្រូវផ្តន្ទាទោស អំពើខុសច្បាប់ទាំងនេះតាមបញ្ញត្តិសមស្របទៅតាមទម្ងន់ទោស ។

ឃ/ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ

មាត្រា៩ (ចំណុចលេខ៥) : ជនណាដែលរងគ្រោះដោយសារការចាប់ខ្លួន ឬ ឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ ត្រូវមានសិទ្ធិពេញទីក្នុងការប្តឹងទាមទារសំណងជំងឺចិត្ត (ប្តឹងទៅអាជ្ញាធរដែលចាប់ចងនោះសងជំងឺចិត្ត) ។

**ចប់**


អំពើទារុណកម្ម
ការរំលោភសិទ្ធិមនុស្ស
ប្រឆាំងនឹងច្បាប់
ជាតិ -អន្តរជាតិ
ត្រូវមានទោស
ដូចអ្នកប្រព្រឹត្តបទល្មើសដែរ

# នគរបាល និង អព្យាក្រិតភាព-យុត្តិធម៌

## I- ឧបសគ្គ:

ដើម្បីថែរក្សាសន្តិសុខសង្គមឱ្យមានរបៀបរៀបរយ គឺមានតែនគរបាលនេះហើយ ដែលមានតួនាទីសំខាន់នៅក្នុងកិច្ចការនេះ ហើយប្រទេសស្ទើរតែទាំងអស់នៅក្នុងសកលលោកក៏ដូច្នេះដែរ ។ គេសង្កេតឃើញកិច្ចការចម្បងបំផុតរបស់នគរបាលគឺថែរក្សាសន្តិសុខសាធារណៈឱ្យមានសុវត្ថិភាពនៅគ្រប់ទីកន្លែង ដោយមិនគិតថាយប់ឬថ្ងៃឡើយ ។ នេះគឺជាអំណាចឬជាសិទ្ធិពិសេសដែលច្បាប់បានកំណត់ឱ្យភ្នាក់ងារនគរបាល មិនថាក្នុងរបបផ្តាច់ការឬរបបប្រជាធិបតេយ្យឡើយ ។ ដូច្នេះ ដើម្បីបំរើកិច្ចការសង្គមឱ្យគួរជាទីកក់ក្តៅ និងសំរាប់ទទួល ការគាំទ្រពីមនុស្សទូទៅ នគរបាលត្រូវតែមានភាពអព្យាក្រិត្យក្នុងតួនាទីនិងភារកិច្ចរបស់ខ្លួន ។ ក៏ប៉ុន្តែគេសង្កេតឃើញមានការកែប្រែតិចតួចណាស់ នៅក្នុងជួរកងកម្លាំងប្រដាប់អាវុធ ចាប់តាំងពីឆ្នាំ១៩៩៣មក ដែលរមែងតែងតែប្រកាន់តឹងនូវនយោបាយរៀង១ខ្លួន ហើយបញ្ហានេះនៅតែមានភាពចាក់ស្រេះសាំញ៉ាំណាស់មកទល់បច្ចុប្បន្ននេះ ទោះបីជាច្បាប់បានចែងពីមុខងារ និង តួនាទីរបស់ភ្នាក់ងារសាធារណៈឱ្យមានជំហរអព្យាក្រិត្យក្នុងការងាររបស់ខ្លួនយ៉ាងណាក៏ដោយ ក៏ប៉ុន្តែតាមការសង្កេតក៏ដូចជាការវាយតម្លៃជាទូទៅឃើញថា បរិយាកាសដែលធ្វើឱ្យមានអព្យាក្រិតភាព និងការគោរពសិទ្ធិមនុស្សនោះក៏មានការប្រែជាបណ្តើរៗ គួរឱ្យកត់សំគាល់ជាអន្លើៗដែរ នៅក្នុងជួរកងកម្លាំងនគរបាលជាតិយើងបច្ចុប្បន្ននេះ ។

នៅក្នុងរបបប្រជាធិបតេយ្យ នគរបាលមិនត្រឹមតែមានអព្យាក្រិតភាពប៉ុណ្ណោះទេ គឺត្រូវតែមានភាពយុត្តិធម៌ថែមទៀតផង បានសេចក្តីថាមិនយកអំណាចរបស់ខ្លួនទៅប្រើឱ្យហួសពីច្បាប់បានចែង ធ្វើឱ្យប៉ះពាល់សិទ្ធិមនុស្សនាំឱ្យអ្នកដទៃខឹងសម្បារ ដាក់បណ្តាសារចំពោះទង្វើទាំងឡាយណា ដែលបង្កឡើងធ្វើឱ្យមានការឈឺចាប់ផ្លូវកាយ-ចិត្ត -ភេទ និង ធ្វើឱ្យបាត់បង់សេចក្តីថ្លៃថ្នូររបស់មនុស្សជាដើម ។

## II- ករណីសិក្សា :

### ១.ករណីសិក្សាទី១

ប្រធាននគរបាលនៃប៉ុស្តិ៍ឃុំមួយ ធ្លាប់មានអារម្មណ៍ជិតជាប់ទៅនឹងជំនឿនយោបាយរបស់គណបក្សមួយ ឈ្មោះគណបក្ស ( ព្រះចន្ទ ) ។ ប្រជាជនឃុំនោះធ្លាប់ទទួលរងនូវអំពើប្លន់ និងចាប់ជំរិតជាច្រើនលើកច្រើន សាក៏ប៉ុន្តែកងកម្លាំងនគរបាលឃុំនោះកម្រចាប់បានជនប្រព្រឹត្តបទល្មើសណាស់ ។ គេតែងតែឮការត្អូញត្អែរ របស់បងប្អូនអ្នកភូមិបារម្ភពីសន្តិសុខរបស់ពួកគាត់ ហើយនិយាយថា : យើងមិនដឹងជាពឹងទៅលើអ្វី បើពួកក្រុមប្លន់សុទ្ធតែមានអាវុធ ហើយសេចក្តីសង្ឃឹមរបស់យើងគឺមានតែនគរបាលប៉ុណ្ណោះ ។ ពេលនោះ មានអ្នកភូមិម្នាក់បាននិយាយថា គាត់បានឮប្រធាននគរបាលប៉ុស្តិ៍នោះនិយាយខ្សឹបៗជាមួយក្រុម ពួកគេនៅ ក្នុងហាងកាហ្វេថា : ពួកចោរទាំងនោះចង់ចាប់ម៉ោងណាបានម៉ោងហ្នឹង តែប្រជាជនឃុំនេះ កន្លងមកមិនបានបោះឆ្នោតឱ្យគណបក្សព្រះចន្ទទេ ពួកគាត់គាំទ្រតែគណបក្សព្រះអាទិត្យប៉ុណ្ណោះ ម៉េចក៏ មិនទៅរកគណបក្សព្រះអាទិត្យឱ្យជួយការពារពួកខ្លួនទៅ ?

ប្រធាននគរបាលប៉ុស្តិ៍នោះបាននិយាយបន្តទៀតថា ម្យ៉ាងទៀតកូនប៉ូលីសរបស់ខ្ញុំ ១នាក់២ដែលធ្លាប់ តែ គាំទ្រគណបក្សព្រះចន្ទនោះ គ្នាធ្លាប់បានរស់ដោយសារក្រុមអន្ធពាលទាំងនោះ រួមទាំងខ្ញុំផងដែរអញ្ចឹង ធ្វើភ-ថ្លង់ខ្លះទៅ! ចាំថ្នាក់លើរឹតខ្លាំងសឹមគិត ។

★ **សំនួរពិភាក្សា :**

1-តើមានបញ្ហាអ្វីខ្លះនៅក្នុងករណីសិក្សានេះ ?

2-តើវាមានបញ្ហាដូច្នេះមែនទេ នៅក្នុងជួរនគរបាលនោះ ? ពិត ? ឬមិនពិត ? ហេតុអ្វី?

3-តើមានផលប៉ះពាល់អ្វីខ្លះដល់ជនរងគ្រោះ និង សង្គម ?

4-តើមានដំណោះស្រាយណាដែលប្រសើរ ចំពោះបញ្ហាទាំងនោះ ? ចូរផ្តល់យោបល់ ។

### ២.ករណីសិក្សាទី២

នគរបាលប៉ុស្តិ៍ម្នាក់ មានតួនាទីជាបណ្តាញឱ្យនគរបាលយុត្តិធម៌ប្រចាំប៉ុស្តិ៍ឃុំ ។ លោកនគរបាលប៉ុស្តិ៍នេះ តែងតែរកលេសបដិសេធជានិច្ចអំពីពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ទោះជាពាក្យបណ្តឹងទាំងនោះទាក់ទង

ទៅនឹងបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។ គាត់តែងប្រាប់អ្នកមកប្ដឹងថា ប៉ូលីសប្រាក់ខែតិចណាស់ បើអ្នកណាមកដាក់ពាក្យបណ្ដឹង មិនជួយប៉ូលីសខ្លះម៉េចនឹងរស់ ! ។ ដូច្នេះជាបឋម បើមកប្ដឹងទាល់តែមានលុយខ្លះសិនទើបទទួល ឯរឿងដោះស្រាយផ្សេងទៀត ។ ម្យ៉ាងវិញទៀតគាត់តែងតែណែនាំអ្នកដែលចង់ប្ដឹងឡើងទៅលើតាមផ្លូវច្បាប់ថា : មិនបាច់ប្ដឹងឡើងទៅលើទេ ត្រឹមហ្នឹងបានហើយ ទោះរឿងប៉ុណ្ណាក៏ប៉ូលីសដោះស្រាយចេញដែរ ប្ដឹងឡើងទៅលើអស់លុយច្រើនណាស់ បើខាងក្រោមអស់១ ទៅលើច្បាស់ជាអស់ ៤-៥ មិនខានឡើយ មិនស្រួលអស់ហើយ គោ-ក្របី-ផ្ទះសម្បែងនោះ ។ល។

★ **សំនួរពិភាក្សា**

1-តើមានបញ្ហាអ្វីខ្លះនៅក្នុងករណីសិក្សានេះ ?

2-តើវាមានបញ្ហាដូច្នេះមែនទេ នៅក្នុងជួរនគរបាលនោះ ? ពិត ឬមិនពិត ? ហេតុអ្វី?

3-តើមានផលប៉ះពាល់អ្វីខ្លះដល់ជនរងគ្រោះ និង សង្គម ?

4-តើមានដំណោះស្រាយណាដែលប្រសើរចំពោះបញ្ហាទាំងនោះ ? ចូរផ្ដល់យោបល់ ។

## III. សំនួរផ្សេងៗ :

1-តើនគរបាលអាចបដិសេធ ពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋបានទេ ? ហេតុអ្វី ?

2-តើនគរបាលអាចសំរុះសំរួលរឿងក្ដីព្រហ្មទណ្ឌបានដែរឬទេ ? ហេតុអ្វី ?

## IV. អត្ថបទជំនួយ

១.<u>មុខងារទូទៅរបស់នគរបាល</u> : នគរបាលមានមុខងារទូទៅមួយនៅក្នុងសង្គម គឺរក្សានូវរបៀប រៀបរយ មានសណ្ដាប់ធ្នាប់សាធារណៈ ការពារប្រជាជន និងបង្ការបទល្មើស ។ ស្ថាប័នជំនាញរបស់នគរបាលមួយចំនួនដែលហៅថានគរបាលយុត្តិធម៌ ឬនគរបាល តុលាការ មានសមត្ថកិច្ចក្នុងការស៊ើបអង្កេតបទល្មើស ដូចជាចាប់ខ្លួននិងឆែកឆេរជាដើម។

២.<u>ក្រមសីលធម៌របស់នគរបាលជាតិ</u> :

មួយចំនួនដែលហៅថានគរបាលយុត្តិធម៌ ឬនគរបាល តុលាការ មានសមត្ថកិច្ចក្នុងការស៊ើបអង្កេតបទល្មើស ដូចជាចាប់ខ្លួននិងឆែកឆេរជាដើម។

២.ក្រមសីលធម៌របស់នគរបាលជាតិ :

ក្នុងនាមជានគរបាលជាតិកម្ពុជា មានភារកិច្ចដូចតទៅ :

-ការអោយជីវិត សិទ្ធិ ភាពថ្លៃថ្នូររបស់ប្រជាពលរដ្ឋទាំងអស់ និងសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ទ្រព្យសម្បត្តិឯកជននិងសាធារណៈ ។

-រក្សាសន្តិសុខ សុវត្ថិភាព និងរបៀបរៀបរយសាធារណៈ ។

-ការពារនិងអង្កេតបទល្មើស ។

-ជួយសាធារណជនក្នុងកាលទេសៈមានគ្រោះអាសន្នបន្ទាន់ ។

៣.ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋកម្ពុជា :

មាត្រា ៣៥ : នគរបាលយុត្តិធម៌ ស្វែងរកបទល្មើសឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទាំងឡាយ ប្រមូលភស្តុតាង ហើយបញ្ជូនជនល្មើសទៅសាលាជំរះក្តីដែលមានភារកិច្ចផ្តន្ទាទោសជនទាំងនោះ ។ ប៉ុន្តែជនល្មើសអាចត្រូវបានចាប់បញ្ជូនទៅសាលាជំរះក្តីដោយនគរបាលយុត្តិធម៌តែក្នុង ករណីជនល្មើសបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ឬ កាលណាមានដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាចាប់ខ្លួនជនល្មើស ។

មាត្រា៣៨ (កថាខណ្ឌ១) :

មន្ត្រីនគរបាលយុត្តិធម៌ទទួលពាក្យបណ្តឹងទាមទារបណ្តឹងបរិហារព្រមទាំងរបាយការណ៍នគរ បាលយុត្តិធម៌ទាក់ទងបទឧក្រិដ្ឋ បទមជ្ឈិមនិងបទ លហុនានា ។

៤. មុខងារ/អំណាច របស់នគរបាលយុត្តិធម៌ :

នគរបាលយុត្តិធម៌ អនុវត្តនូវភារកិច្ចសំខាន់ៗដូចជា : ការទទួលពាក្យបណ្តឹង ស៊ើបអង្កេតបទល្មើស សួរចម្លើយជនសង្ស័យនិងសាក្សី ប្រមូលភស្តុតាង និងរៀបចំរបាយការណ៍ឱ្យ ព្រះរាជអាជ្ញា។ល។ នគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជអាជ្ញា ។ នគរបាលយុត្តិធម៌ មិនមានអំណាច ក្នុងការសម្រុះសម្រួលរឿងក្តីព្រហ្មទណ្ឌបានទេ ផ្ទុយទៅវិញត្រូវបញ្ជូនរាល់សំណុំរឿង ទាំងអស់

ទៅឱ្យព្រះរាជអាជ្ញា។ នគរបាលយុត្តិធម៌មានអំណាចមួយចំនួន ដូចជា ចាប់ខ្លួន ឆែកឆេរនិងឃុំឃាំង ប៉ុន្តែអំណាចទាំងនេះត្រូវប្រើប្រាស់ក្នុង ដែនកំណត់មួយត្រឹមត្រូវដោយមិនអាចបំពារបំពានបានឡើយ ។ អ្នកដែលអាចបំពេញមុខងារជានគរបាលយុត្តិធម៌នៅក្របខណ្ឌមូលដ្ឋានបាន ដូចជា : អធិការនគរបាលស្រុក ខណ្ឌ និងប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលដែលទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌជាដើម ។

——ចប់——

# នគរបាល និង ជីវភាព សន្តិសុខផ្ទាល់ខ្លួន

## I.ទស្សនៈ

តាមក្រិត្យក្រមធម្មជាតិ លក្ខខណ្ឌមួយរបស់មនុស្សក្នុងចំណោមលក្ខខណ្ឌឯទៀត គឺត្រូវតែទទួលបាននូវចំណីអាហារគ្រប់គ្រាន់ ឬអាចនិយាយថាល្មមរស់បាន នេះគឺជាចំណុចអាទិភាពរបស់មនុស្ស ។ មានទស្សនៈមួយបានអះអាងថា នៅក្នុងសង្គមជាតិនៃមនុស្សឬក៏នៅក្នុងប្រទេសមួយ ច្បាប់ធំៗគឺមានពីរតែប៉ុណ្ណោះ : ទី១ គឺជាច្បាប់ធម្មជាតិ និង ទី២ គឺជាច្បាប់ដែលអនុមត័ដោយរដ្ឋ ។ ទស្សនៈខាងលើនេះបានអះអាងបន្តទៀតថា ការអនុមត័ច្បាប់ដោយរដ្ឋសំរាប់ការអនុវត្តន៍នៅក្នុងប្រទេសរបស់ខ្លួនត្រូវអនុលោមទៅតាមច្បាប់ធម្មជាតិជាដាច់ខាត បើមិនដូច្នោះទេសង្គមនោះឬថ្នាក់ដឹកនាំនៃប្រទេសនោះប្រាកដជាទទួលនូវការបរាជ័យ បានន័យថា បាត់ការគាំទ្រពីប្រជាពលរដ្ឋរបស់ខ្លួនដែលមិនអាចជៀសវាងបានឡើយ ។ តាមក្រិត្យក្រមធម្មជាតិ មនុស្សមានសិទ្ធិសេរីភាពតាំងពីកំណើត ដូចជាត្រូវទទួលបាននូវចំណីអាហារគ្រប់គ្រាន់ មានសម្លៀកបំពាក់ មានជំរក ទទួលការថែទាំសុខភាព និយាយស្តី ឬមានចលនា។

ចំណុចទាំងអស់នេះ គឺជាអត្តសញ្ញាណសំខាន់របស់មនុស្សដែលបានផ្តល់ឱ្យតាំងពីកំណើត ហើយដែលបានទទួលការគ្រប់គ្រង និងថែទាំដោយយកចិត្តទុកដាក់ពីឪពុកម្តាយនិងសង្គម ។ ផ្ទុយទៅវិញបើមនុស្សបួបមិនបានឆ្អែត ត្រូវគេប្រើឱ្យធ្វើការជាទម្ងន់ ខ្វះការថែទាំ និយាយស្តីដើរហើរមានកំរិត ឬឆ្លងកាត់ទំនាក់ទំនងមិនបាន កេងប្រវញ្ចន៍ ប្រើអំពើឃោរឃៅ ផ្តាច់ការ ជាពិសេសបំបាត់ជីវិតមនុស្សដូចសត្វធាតុ ។ល។ ចំណុចទាំងអស់នេះ គឺជាការប្រឆាំងពេញទីទៅនឹងក្រិត្យក្រមធម្មជាតិនៃមនុស្សជាតិហើយ ។ សង្គមជាតិ ឬថ្នាក់ដឹកនាំ ឬជាភ្នាក់ងារដែលបានអនុវត្ត និង មានទង្វើដូចពោលខាងលើ ដាច់ខាតត្រូវតែទទួលនូវការបរាជ័យមិនខានឡើយ ។

បច្ចុប្បន្ននេះយើងសង្កេតឃើញថា ការអនុម័តរាល់ច្បាប់របស់ប្រទេសកម្ពុជាយើងគឺវាបានស្របទៅនឹងច្បាប់ធម្មជាតិនៃមនុស្សហើយ ក៏ប៉ុន្តែមនុស្សមួយចំនួនដែលមានអំណាច មានឥទ្ធិពល ដើម្បីបំពេញនូវសេចក្តីត្រូវការ និង សន្តិសុខផ្ទាល់ខ្លួនរបស់គេ គេមិនបានគិតពីសន្តិសុខផ្ទាល់ខ្លួនរបស់អ្នកដទៃឡើយ ដូច្នេះបណ្តាលឱ្យអំពើអយុត្តិធម៌កើនឡើងយ៉ាងខ្ពស់ ការរំលោភសិទ្ធិមនុស្សកាន់តែធ្ងន់ធ្ងរឡើងៗ ឯផល

វិបាកគ្រប់ជំពូកនឹងធ្លាក់ទៅលើប្រជាពលរដ្ឋសាមញ្ញ និងភ្នាក់ងារណាដែលអនុវត្តច្បាប់ និង ពិតជាមានទំនាញសង្គមទំនោរទៅរកការបរាជ័យ បើសិនជាជីវភាពរស់នៅរបស់មនុស្សកាន់តែដុនដាបទៅៗនោះ ។

## II. ករណីសិក្សា

នៅក្នុងតៀមកាហ្វេនាថ្ងៃអាទិត្យមួយ មានភ្នាក់ងារមួយក្រុម កំពុងតែជជែកគ្នាពីនេះពីនោះ ទាក់ទងនឹងជីវភាពរបស់ពួកគេ ។ នគរបាលម្នាក់បានត្អូញត្អែរថា តើថ្ងៃណាទៅ យើងនឹងទទួលបានប្រាក់ខែគ្រប់ល្មមសំរាប់មួយខែៗនោះ ? រំពេចនោះស្រាប់តែមានគ្រូបង្រៀនម្នាក់និយាយថា ឯងមិនគួរត្អូញទេ គ្នាឯណេះវិញទេដែលត្រូវត្អូញនោះ ព្រោះគ្នាដូចពស់ព្រលិតអញ្ចឹង ។ លោកគ្រូនោះនិយាយមិនទាន់ចប់ផងស្រាប់តែមានលោកម្នាក់ទៀតនិយាយកាត់ថា ពួកឯងទាំងពីរអាចបង្គ្រប់ណេះណុះបាន បើពួកឯងទាំងពីរថ្ងូរដូចព្រាបទៅហើយនោះ តើយើងដែលជាភ្នាក់ងារ ក្រសួងធម្មការធ្វើការតែ ជាមួយព្រះសង្ឃទៅរំពឹងអីបាន! កូនស៊ីសៀងហើយឥឡូវនេះ ។ ពេលនោះមានប៉េអឹមម្នាក់ និយាយថា គ្មានអ្នកណា ចេះដេកងាប់ទេរើយ! ពួកឯងមើលអីនៅលើម៉ូតូគ្នានេះ? គ្រាន់តែគ្នាជិះកាត់មុខផ្ទះ គេហៅ ឱ្យមួយកែសភ្លាម ។ ចំណែកពួកឯងគ្រប់ៗគ្នា បើមិនចេះច្នៃប្រឌិតដើម្បីរស់ទេនោះ ឱ្យវាស្លាប់ទៅចុះ! តែគ្នាឃើញ ក្រុមពួកឯងភាគច្រើនមិនជាអន់ដូចជាឯងទាំងបីនាក់នេះទេរើយ ខ្លះគេមានរហូតដល់ឡានជិះទៀតផង ហើយប្រាក់ខែគេក៏តិចដូចជាពួកឯងដែរ ។ គ្នាប្រាប់មិត្តដឹងឯងខ្លះៗទៅចុះ សព្វថ្ងៃនេះអ្នកខ្លះដែលគេធ្វើការនឹងច្បាប់ គេចាត់ ទុកច្បាប់គ្រាន់តែជាខែល សំរាប់អំពើកេងប្រវញ្ចន៍ពីជនរងគ្រោះ ឬ ពីអតិថិជនតែប៉ុណ្ណោះ បានន័យថា បើអ្នកណាស្នើអ្វីមួយឱ្យជួយដោះស្រាយតាមផ្លូវច្បាប់ ហើយចង់ឱ្យបានទទួលផលវិជ្ជមានភ្លាមៗនោះ គឺមានតែទេវប្រាក់ទេ ចង់អ្នកណាកើត ទុកសោកសង្រេងយ៉ាងណាក៏ដោយគឺមិនឈឺក្បាលពួកគេឡើយ ។ ប៉េអឹមនោះនិយាយបន្តទៀតថា តាមគ្នាដឹងភ្នាក់ងារក្រសួងធម្មការខ្លះ ប្រហែលជាយកកុម្ម៉ីស្យុងពីព្រះសង្ឃទៅតាមចំណូលវត្តអារាម ដូច្នេះគេអាចរស់បាន ហើយឯងជាភ្នាក់ងារធម្មការដែរនោះគួរតែគិតគូរសាថ្មីឡើងវិញ ។ ចំពោះគ្រូបង្រៀនវិញ យើងនិយាយត្រឹមកំរិតមធ្យមសិក្សាទៅចុះ តាមគ្នាដឹងគ្រូសៗក៏គេមានក្រលារស់របស់គេដែរ គឺនៅកន្លែងខ្លះជំរិតសិស្សខ្លួនឯងឱ្យរៀនបង់ថ្លៃក្រៅម៉ោង បើសិស្សណាមិនរៀនត្រូវគ្រូគំរាមថា វិញ្ញាសាដែលចេញប្រលងគឺមាននៅពេលរៀនក្រៅម៉ោង បើអ្នកណាមិនរៀនប្រយត្ន័មិនបានឡើងថ្នាក់ ។ ឬ មួយក៏គ្រូខ្លះសម័យឥឡូវលក់សព្វ លក់គ្រប់ លក់តាំងពីមេរៀន ឬក៏នំកំប៉ិកកំប៉ុកផ្សេងៗសព្វគ្រប់តាមឯកទេសរៀងៗខ្លួន មិនថាថ្នាក់ណាជាថ្នាក់ណាទេ

ឬតាំងពី មធ្យមសិក្សាកំរិតទាបទៅ ។

ចំណែកឯនៅតាមសាលាបឋមសិក្សាខ្លះ គឺឱ្យសិស្សបង់ថ្លៃជាទៀងទាត់ពី ២០០ដល់ ៥០០រៀល ទៅតាមកំរិតថ្នាក់ ដូច្នេះបើគ្រូធ្វើដូច្នេះគេអាចរស់បាន។ ចំណែកឯផ្នែកដទៃទៀតដូចជាផ្នែកផ្សព្វផ្សាយពត៌មាន មានទូរទស្សន៍ខ្លះជាដើម ដើម្បីរកថវិកាចិញ្ចឹមភ្នាក់ងាររបស់គេ ទោះបីជាសិល្បៈវប្បធម៌ខ្លះមាន លក្ខណៈបែបអាសអាភាសក៏គេគិតថា លុយកាក់សំរាប់ចិញ្ចឹមជីវិតភ្នាក់ងាររបស់គេវាប្រសើរជាង ។ល។ លោកប៉េអឹមនោះបន្តទៀតថា ពួកឯងដឹងស្រាប់ហើយ ប្រទេសយើងកំពុងក្រលាស់ បានលុយឯណាតម្លើងប្រាក់ខែឱ្យពួកឯងបានទាន់ចិត្តនោះ ?

**★សំនួរពិភាក្សា**

១-ចូរស្រង់បញ្ហាទាំងអស់ដែលមាននៅក្នុងករណីសិក្សាខាងលើនេះ ។

២-យោងតាមករណីសិក្សាខាងលើនេះ វាជារឿងពិតឬមិនពិត ? ហេតុអ្វី ?

៣-តើមានផលប៉ះពាល់អ្វីខ្លះដល់ប្រជាពលរដ្ឋ និង សង្គម ?

៤-តើមានដំណោះស្រាយដូចម្តេចដែលប្រសើរ ចូរផ្តល់យោបល់ ?

## III. ច្បាប់ពាក់ព័ន្ធ

**✱កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ :**

__មាត្រា៧__ : រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិមនុស្សរាល់រូបក្នុងការអាស្រ័យផលនៃការងារដែលមានលក្ខខណ្ឌត្រឹមត្រូវនិងសមរម្យ ហើយដែលធានាជាពិសេសនូវ :

ក/ លាភការ សំរាប់អ្នកធ្វើការទាំងអស់ក្នុងកំរិតអប្បបរមានូវ :

១-ប្រាក់កំរៃសមរម្យ និងលាភការស្មើគ្នាចំពោះការងារដែលមានគុណភាពស្មើៗគ្នា មិនថាជាប្រភេទការងារណាៗឡើយ ជាពិសេសគឺនារី ដែលត្រូវតែឱ្យប្រាក់ខែស្មើគ្នានឹងបុរស ចំពោះការងារដូចគ្នា ។

២-ជីវភាពរស់នៅយ៉ាងសមរម្យ សំរាប់ខ្លួនឯងផងនិងសំរាប់គ្រួសារផង សមស្របទៅតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ ។

ខ/ លក្ខខណ្ឌការងារ ដែលប្រកបដោយភាពឥតគ្រោះថ្នាក់និងធានាដល់សុខភាព ។

គ/ សមភាពក្នុងការតម្លើងឋានន្តរស័ក្តិ ដោយឥតសំអាងទៅលើអ្វីៗក្រៅតែពីគុណសម្បត្តិ ការពិសោធន៍ និងភាពចាស់វស្សានៃការងារ ។

ឃ/ ការសំរាក ការលំហែ ការកំរិតម៉ោងពេលធ្វើការ សមហេតុសមផលត្រឹមត្រូវ ការឈប់សំរាកក្នុងថ្ងៃបុណ្យដោយមានប្រាក់កំរៃ ព្រមទាំងលាភការនៅឱកាសវិស្សមកាលសាធារណៈផង ។

មាត្រា១១ : រដ្ឋជាភាគីទាំងឡាយ ទទួលស្គាល់នូវសិទ្ធិរបស់មនុស្សម្នាក់ៗ ក្នុងការមានជីវិតរស់នៅដ៏សមរម្យ សំរាប់ខ្លួនគេផ្ទាល់ និងសំរាប់គ្រួសារគេ រួមទាំងចំណីអាហារគ្រប់គ្រាន់ សំលៀកបំពាក់និងទីលំនៅ ព្រមទាំងសម្ភារៈផ្សេងៗ សំរាប់ធ្វើការរស់នៅបានប្រសើរឡើងជាលំដាប់ ។

**មាត្រា១២** : រដ្ឋភាគីទាំងឡាយ ទទួលស្គាល់នូវសិទ្ធិមួយដែលចែងថា បុគ្គលគ្រប់រូបមានសិទ្ធិរស់នៅប្រកបដោយសុខុមាលភាពយ៉ាងប្រពៃ ទាំងផ្នែករាងកាយ ទាំងផ្នែកគំនិតប្រាជ្ញា ។

**ចប់**

# នគរបាល និងការការពារជីវិតមនុស្ស

**I.ឧស្សនៈ** ជីវិតមនុស្សគ្មានលក់នៅទីផ្សារឡើយ ឬក៏គ្មានអ្នកណាម្នាក់ចង់ស្លាប់ទៅវិញទេ ទោះជាអ្នកនោះមានអាយុដល់១០០ឆ្នាំ ឬ មួយក៏មានជម្ងឺយ៉ាងធ្ងន់ធ្ងរហៀបដាច់ខ្យល់ស្លាប់យ៉ាងណាក៏ដោយ ។ ប្រសិនបើមានជនណាម្នាក់ត្រូវគេសម្លាប់ ហើយគាត់ជាជំហរក្នុងគ្រួសារមួយដែលមានសភាពក្រីក្រ ជននោះប្រាកដជាស្លាប់ទៅដោយបិទភ្នែកមិនជិតឡើយ ទោះបីជាគាត់បានភ្ញាក់ស្មៀតឬរំលោភដោយប្រការណាមួយទៅលើអ្នកដទៃយ៉ាងណាក៏ដោយ ។ ដូច្នេះអ្វីដែលមនុស្សគ្រប់ៗគ្នា ត្រូវការសំខាន់បំផុតជាងគេ នោះគឺ "សិទ្ធិរស់រានមានជីវិត" ផ្ទុយទៅវិញបើមនុស្សកើតមកហើយៗត្រូវគេបំបាត់ជីវិតទៅវិញ ដោយ អំពើឃោរឃៅអមនុស្សធម៌នោះ មានន័យថាទង្វើនេះគឺចាត់ទុកមនុស្សដូចជាសត្វតិរច្ឆាន ។

សិទ្ធិមនុស្ស ក៏ដូចជាច្បាប់របស់ប្រទេសកម្ពុជាដែរ បានប្រឆាំងយ៉ាងដាច់ខាតចំពោះអំពើនេះចាប់តាំងពីឆ្នាំ១៩៩២-៩៣មក ក៏ប៉ុន្តែការសម្លាប់មនុស្សក្រៅច្បាប់នៅតែមានជាបន្តរហូតមកទល់បច្ចុប្បន្ននេះ។ តើមកពីហេតុអ្វី ? តាមការសន្និដ្ឋាន វាបណ្តាលមកពីការយល់ឃើញរបស់មតិមួយចំនួននៅក្នុងចំណោមកងកម្លាំងប្រដាប់អាវុធគិតថា ជនប្រព្រឹត្តបទល្មើសដូចជា លួច ប្លន់ជាដើម គួរតែសម្លាប់ចោលខ្លះទើបពួកគេរាងចាល ។ ក៏ប៉ុន្តែគេតែងសង្កេតឃើញថា ក្រៅពីបាញ់ប្រហារមនុស្សដោយចេតនាបែបចំហហើយ គឺមានការលួចបាញ់មនុស្សដោយសម្ងាត់ថែមទៀតផង អាចបណ្តាលមកពីមូលហេតុច្រើនយ៉ាង ដូចជារឿងផ្ទាល់ខ្លួន ការលោបពណ៌ឱ្យបុគ្គល ជាហេតុផលនយោបាយ ជាពិសេសនៅពេលបោះឆ្នោតក្នុងការប្រកួតប្រជែងរកសម្លេងគាំទ្រ ។ល។ ចំពោះអ្នកសម្លាប់មនុស្សជាបន្តបន្ទាប់ទាំងចំហក៏ដូចជាសម្ងាត់បានពិនិត្យ ឃើញលទ្ធផលតិចតួចណាស់ដែលយកឧក្រិដ្ឋជនទាំងនោះទៅផ្តន្ទាទោសតាមផ្លូវច្បាប់ ។ ក្រៅពីនេះក៏មានមតិខ្លះចង់បញ្ចុះបញ្ចូលស្ថាប័នច្បាប់ឱ្យកែប្រែរដ្ឋធម្មនុញ្ញ ធ្វើឱ្យមានចែងពីការសម្លាប់មនុស្សចំពោះឧក្រិដ្ឋជន ដោយអះអាងថា វាមានភាពងាយស្រួលក្នុងការគ្រប់គ្រងសន្តិសុខសង្គម ។

*តើការបញ្ចុះបញ្ចូល ឱ្យមានការកែប្រែច្បាប់នេះ វានាំឱ្យសង្គមអស់ជនខិលខូច ឬចាត់ទុកថាជាដំណោះស្រាយល្អ ពិត ឬ មិនពិត ?*

# អ្នកដែលចោមរោមវាយសម្លាប់ជនល្មើស
# ត្រូវមានទោសពីបទធ្វើឃាតកម្ម



ជនល្មើសក៏មានទោស

អ្នកចោមរោមវាយជនល្មើសក៏មានទោស



## II.សំនួរពិភាក្សា :

១.ពិភាក្សារកហេតុផលសមរម្យ សំរាប់គាំទ្រទៅលើមតិខ្លះដែលយល់ថា ដើម្បីគ្រប់គ្រងសន្តិសុខសង្គមបានល្អ លុះត្រាតែឧក្រិដ្ឋជនត្រូវបានប្រហារជីវិត ទើប អ្នកដទៃទៀតមិនយកគំរូតាម ។

២.ពិភាក្សារកហេតុផលសមរម្យ សំរាប់គាំទ្រទៅលើមតិដែលយល់ថា កត្តាដែលនាំឱ្យមានការគ្រប់គ្រងសន្តិសុខសង្គមបានល្អអាចមានចំណុចល្អៗមកជំនួសបានយ៉ាងប្រសើរដោយមិនបាច់សម្លាប់មនុស្ស (ឧក្រិដ្ឋជន) ឡើយ ។

៣.ពិភាក្សារកហេតុផលថា (តាមយោបល់ផ្ទាល់ខ្លួន ) ហេតុអ្វីបានជាច្បាប់របស់ប្រទេស កម្ពុជាហាមទោសប្រហារជីវិត ?

៤.ពិភាក្សារកហេតុផលថា តើវាបណ្ដាលមកពីមូលហេតុអ្វីខ្លះ ដែលនាំឱ្យកើតជន ឬក្រុមទុច្ចរិតដូចជា : លួចប្លន់ ចាប់ជំរិត ជួញដូរមនុស្ស (ជួញយកទៅធ្វើជា ពេស្យាចារ)យ៉ាងច្រើនដូច្នេះ ? ហើយថា តើវាមកពីអ្វីទៀតទៅ ដែលជនទុច្ចរិត ខាងលើនេះនៅតែកើតមានយ៉ាងសកម្មដូច្នេះ ?

## III.អត្ថបទជំនួយ

**១.ឥស្សរៈព្រះពុទ្ធសាសនា :** រាប់ពាន់ឆ្នាំមកហើយ ដែលខ្មែរស្ទើរតែ១០០% មានជំនឿលើព្រះពុទ្ធសាសនា។

សព្វថ្ងៃនេះព្រះពុទ្ធសាសនាបានចែងក្នុងច្បាប់កំពូលថាជាសាសនារបស់រដ្ឋ ។ ដូច្នេះតាមរយៈ ព្រះពុទ្ធសាសនានេះ បានចាក់ឫសឱ្យខ្មែរប្រកបទៅដោយជំនឿយ៉ាងមុតមាំ ពោលគឺប្រដៅមនុស្សឱ្យប្រកាន់នូវអំពើល្អ ចេះជួយចែករំ លែកគ្នា ចេះសន្ដោសគ្នា អត់ឱន អត់ធ្មត់ មិនឱ្យលោភលន់ អ្នកធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ពៀរមិន ត្រូវសងដោយពៀរ ។ល។ ផ្ទុយទៅវិញចំពោះអ្នកប្រព្រឹត្តអំពើមិនល្អដូចជា លួចប្លន់ រំលោភប្រពន្ធកូនប្ដីគេ រើសម្លាប់អ្នកដទៃ សម្លុតគំរាម គឺជាបញ្ញត្តិយ៉ាងតឹងរឹង ណាស់សំរាប់ ធម៌វិន័យព្រះពុទ្ធសាសនា ។ ដូច្នេះអាច និយាយបានថា ការគោរពព្រះពុទ្ធសាសនា តាំងពីយូរលង់ណាស់ មកហើយនោះ មានន័យថាជាការគោរព សិទ្ធិមនុស្សដែរ ។

*ចុះហេតុអ្វី បានជាយើងកាប់សម្លាប់គ្នាដោយឥតញញើតដៃនៅពីរបីទសវត្សរ៍ចុងក្រោយនេះ ?*

មានហេតុពីរយ៉ាង :

1-គឺបណ្ដាលមកពីសង្គ្រាមដណ្ដើមអំណាចគ្នា

2-មានទមិឡប់បាត់សាសនាក្នុងអំឡុងសង្គ្រាមហើយសម្លាប់គ្នាឯងដូចសត្វធាតុ ជាលទ្ធផលធ្វើឱ្យបាត់បង់ធនធានមនុស្សពីរឬបីជំនាន់ ដែលបន្សល់ឱ្យមនុស្សមានចិត្តឃោរឃៅ អវិជ្ជា ចំណេះដឹងធ្លាក់ចុះ និងបាត់បង់នូវសីលធម៌ ប្រពៃណី និង ទំនៀមទម្លាប់ល្អៗរបស់ សង្គម ។ល។

ដូច្នេះ ក្នុងនាមខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា យ៉ាងហោចណាស់ក៏ត្រូវចេះរក្សាសីល៥ មានដូចជា :

1-បាណាតិបាតា ( ហាមសម្លាប់)

2-អទិន្នាទានា ( ហាមលួចប្លន់គេ)

3-កាមេសុមិច្ឆា ( ហាមរំលោភប្រពន្ធ-កូន-ប្ដីគេ)

4-មុសាវាទាវេ ( ហាមនិយាយដើម និង កុហកគេ)

5-សុរាមេរយ ( ហាមគ្រឿងស្រវឹង)

ដើម្បីជាទម្លាប់ល្អ គឺការគោរពសេចក្ដីសុខអ្នកដទៃ មិនបៀតបៀនអ្នកដទៃ មិនឱ្យអ្នកដទៃឈឺចាប់ដោយសារខ្លួន ជាពិសេសកុំមានចេតនាបំបាត់ជីវិតគេសោះឡើយ ។

## ២.ច្បាប់របស់ប្រទេសកម្ពុជា

**1-<u>សេចក្ដីប្រកាសជាសាកលស្ដីអំពីសិទ្ធិមនុស្ស</u>**

<u>មាត្រា៣</u> : មនុស្សម្នាក់ៗមានសិទ្ធិរស់រានមានជីវិត និងសន្តិសុខផ្ទាល់ខ្លួន ។

**2-<u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា</u>**

<u>មាត្រា៣២</u> : ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។ ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**3-<u>កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយ</u>**

<u>មាត្រា៦</u> (កថា.១) បុគ្គលគ្រប់រូបមានសិទ្ធិរស់រានមានជីវិត ជាប់តាំងពីកំណើត ។ ច្បាប់នេះត្រូវបានការពារសិទ្ធិនេះជាដាច់ខាត ។ គ្មានបុគ្គលណាម្នាក់ត្រូវគេដកហូតជីវិតរបស់គាត់តាមតែអំពើចិត្តបានឡើយ ។

**4-<u>ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល</u>**

មាត្រា៦៧ : ទោសប្រហារជីវិត ត្រូវបានលប់ចោលនៅប្រទេសកម្ពុជា ។

មាត្រា៣១ ( ឃាតកម្មគិតទុកជាមុន ) :

១/ជនណាដែលសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋ ពី១០ឆ្នាំ ទៅ២០ឆ្នាំ ។

២/ការគិតគូរទុកជាមុន គឺគំរោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាមួយ ។ ការពួនស្ទាក់និងការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តហិង្សាទៅលើបុគ្គលនោះ ។

មាត្រា៣២ ( អំពើមនុស្សឃាតដោយចេតនា ) ជនណាដែលសម្លាប់មនុស្សដោយចេតនា ឬប៉ុនប៉ង សម្លាប់ជនណា ម្នាក់ទៀតដោយចេតនា ដោយគ្មានស្ថានទម្ងន់ណាមួយដែលចែងក្នុងមាត្រា៣១ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវ ផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋ ពី៨ឆ្នាំ ដល់ ១៥ឆ្នាំ ។

មាត្រា៣៣ ( បទរំលោភសេពសន្ថវៈ ) ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភ សេពសន្ថវៈ លើជនណាម្នាក់ទៀត ទោះភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទរំលោភសេព សន្ថវៈ ហើយផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋ ពី៥ឆ្នាំ ដល់ ១០ឆ្នាំ ។

មាត្រា៣៤ ( អំពើប្លន់ ) :

១-ជនណាដែលបានលួច ឬប៉ុនប៉ងនឹងលួចជនណាម្នាក់ទៀត ដោយមានស្ថានទម្ងន់ទោសទាំងនេះ :

-ការលួចធ្វើដោយអំពើហិង្សា មានអាវុធ ឬ ឥតអាវុធ បណ្តាលឬមិនបណ្តាលឱ្យមានរបួស ។

-ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬ ដោយមានគាស់ទម្លុះទម្លាយ ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវមានទោសដាក់គុកជាបទឧក្រិដ្ឋ ពី៣ឆ្នាំទៅ១០ឆ្នាំ ។

២-អំពើលួចប្លន់ គឺការបន្លំ យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**ចប់**

# ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ

## I.ឧបសគ្គ:

ជននានា ដែលបានទទួលការបង្កើនសមត្ថភាពតាមរយៈការអប់រំសិទ្ធិមនុស្ស គួរតប្បីលែលកបន្តផងដែរ នូវការយល់ដឹងរបស់ខ្លួនដល់សាច់ញាតិ អង្គភាពជាមួយ ឬអ្នកជិតខាង ដើម្បីឱ្យគេបានចូលរួមគំនិត ក្នុងការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ ឬក៏ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដែលតែងតែកើតមានជារឿយៗ នៅគ្រប់ទិសទី មិនថាទីក្រុងឬជនបទនោះឡើយ ។

ដោយឡែក នគរបាលមានតួនាទីសំខាន់ណាស់នៅក្នុងសង្គមជាតិ និយាយរួមតួនាទីរបស់ពួកគេគឺជាអ្នកបង្ការបទល្មើសនៅគ្រប់ទីកន្លែង ព្រមទាំងមានអំណាចចាប់ខ្លួន ឃុំខ្លួន និងឆែកឆេរជនសង្ស័យ ជាដើម ។ គួបផ្សំនឹងតួនាទីរបស់នគរបាលដែលមានស្រាប់ ហើយដើម្បីធ្វើឱ្យស្ថានភាពរំលោភសិទ្ធិមនុស្សកាន់តែថយចុះនោះ គឺជាការបង្កើតក្រុមការងារនៅតាមសហគមន៍ដែលមាននគរបាលចូលរួម ។ ក្រុមការងារនេះឈ្មោះថា " **ក្រុមប៉ូលិសសហការ** " គឺមានតួនាទីសហការកាន់តែជិតស្និទ្ធជាមួយក្រុមឯទៀត មានក្រុមប្រជាពលរដ្ឋស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលជាដើម ។

ក្រុមប៉ូលិសសហការ គឺសំរាប់ការពារផលប្រយោជន៍ស្របច្បាប់ ដល់ប្រជាពលរដ្ឋក៏ដូចជាពលរដ្ឋដែលត្រូវគេរំលោភ រួមទាំងនគរបាលផងដែរ ដើម្បីឱ្យកាន់តែប្រសើរជាងមុន ។ ដូច្នេះអ្វីដែលជាយុទ្ធសាស្ត្រសំរាប់ការពារសំខាន់នៅពេលនេះ គឺចង់បានការចេះធ្វើការរួមគ្នា ការសហការគ្នា ឬការបង្កើតនិងចងជាបណ្តាញការងារនឹងគ្នា ដើម្បីដោះស្រាយបញ្ហារំលោភនៅក្នុងសហគមន៍តាមបែបប្រជាធិបតេយ្យ ក្នុងការទប់ទល់ កាត់បន្ថយ លុបបំបាត់ អំពើរំលោភសិទ្ធិមនុស្សដែលបាននិងកំពុងតែកើតមាននោះ ថាតើគួរធ្វើដូចម្តេច ដើម្បីឱ្យឃើញទំនុកចិត្ត និងមានការគាំទ្រពីប្រជាពលរដ្ឋ ។

## II.ការជ្រើសរើសតំណាងក្រុម

ដោយនគរបាលមានមុខងារជាអ្នកបង្ការនិងបង្ក្រាបបទល្មើស ដូច្នេះការបង្កើតក្រុមសហការ នៅក្នុងជួរនគរបាល វានឹងជួយថែមទៀតឱ្យការរំលោភសិទ្ធិមនុស្សកាន់តែថយចុះជាបន្តបន្ទាប់ ។ ដូច្នេះ សមាជិក

# កិច្ចពិភាក្សារកយុទ្ធសាស្ត្រសំរាប់ការពារសិទ្ធិមនុស្ស



ចូលរួមទាំងអស់នឹងបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានក្រុមតាមបែបប្រជាធិតេយ្យ ដើម្បីជួយចាត់ការទៅលើកិច្ចការសិទ្ធិមនុស្សនៅក្នុងសហគមន៍ ឱ្យកាន់តែប្រសើរឡើង ហើយទទឹមនឹងនេះ ថាតើប្រធានធ្វើអ្វី ? អនុប្រធានធ្វើអ្វី ? និងសមាជិកធ្វើអ្វី ?

## III.សម្រង់ចំនួនករណីរំលោភសិទ្ធិមនុស្ស

អ្នកចូលរួមទាំងអស់ ស្រង់ចំនួនករណីរំលោភសិទ្ធិមនុស្ស ដែលបាននិងកំពុងកើតឡើងនៅក្នុង ឃុំ ភូមិ ស្រុក និងពិភាក្សារកដំណោះស្រាយ (ទុកជាគំរូ )ថាតើត្រូវដោះស្រាយដូចម្តេច ?តាមវិធីណា ? បានជំហានណា ? ដោយចុះក្នុងតារាងខាងក្រោមនេះ :

**<u>សំនួរជាឧទាហរណ៍</u> :**

1-តើមានអំពើហិង្សា កើតច្រើនទេ ? ប៉ុន្មានគ្រួសារ ?

2-តើមានអំពើបង្ករបួសស្នាម ឬឃាតកម្មទេ ? បង្ករបួសស្នាមឬឃាតកម្មទៅលើរឿងអ្វីខ្លះ ? ទៅលើអ្នកណា ?

3-តើមានករណីទំនាស់ឬរំលោភដីធ្លីឬទេ ? ប្រហែលប៉ុន្មានករណី ? អ្នកណានឹងអ្នកណា ?

4-តើមានករណីចាប់រំលោភសេពសន្ថវៈ ចាប់ជំរិត ជួញដូរផ្លូវភេទ ឬទេ ?

| ល.រ | ប្រភេទនៃការរំលោភ | ទីកន្លែង(ភូមិ,ឃុំ,ស្រុក) | វិធីដោះស្រាយ | សរុបករណី |
|---|---|---|---|---|
| ១ | ..............................<br>.............................. | ..............................<br>.............................. | ..............................<br>..............................<br>..............................<br>.............................. | .............. |
| ២ | ..............................<br>.............................. | ..............................<br>.............................. | ..............................<br>..............................<br>.............................. | .............. |

## IV. ទម្រង់របាយការណ៍សង្ខេបលើករណីរំលោភសិទ្ធិមនុស្ស

បើសិនជាករណីរំលោភមានលក្ខណៈធ្ងន់ធ្ងរ ករណីទាំងនោះត្រូវតែធ្វើការស៊ើបអង្កេតដោយស្វែងរកពតិមានដែលគួរឱ្យទុកចិត្តបាន ហើយទម្រង់បែបបទដែលត្រូវរាយពតិមាន មាន ដូចខាងក្រោមនេះ :

ក/ឈ្មោះបទរំលោភ

ខ/តើអ្នកណាជាជនរងគ្រោះ ? ឈ្មោះ ភេទ អាយុ មុខងារ ទីលំនៅ( ភូមិ.ឃុំ.ស្រុក.ខេត្ត)

ទីកន្លែងកើតហេតុ ( ភូមិ.ឃុំ.ស្រុក.ខេត្ត) ពេលវេលា ( ម៉ោង.ថ្ងៃ.ខែ.ឆ្នាំ) ។

គ/តើអ្នកណាជាអ្នករំលោភសិទ្ធិមនុស្សរបស់ជនរងគ្រោះ ? ឈ្មោះ.ភេទ.អាយុ.មុខងារ.ទីលំនៅ ( ភូមិ.ឃុំ.ស្រុក.ខេត្ត) ទីកន្លែងកើតហេតុ ( ភូមិ.ឃុំ.ស្រុក.ខេត្ត) ពេលវេលា ( ម៉ោង.ថ្ងៃ.ខែ.ឆ្នាំ) ។

ឃ/វត្ថុតាង ឬមធ្យោបាយ ឬប្រភេទឧបករណ៍ ដែលបានរំលោភទៅលើជនរងគ្រោះ ។

ង/តើមានមាត្រាច្បាប់ណាខ្លះ ដែលត្រូវបានគេរំលោភនោះ ?

## V. ច្បាប់របស់ប្រទេសកម្ពុជា

### ១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

<u>មាត្រា៣២</u> : ជនរាល់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

<u>មាត្រា៤២</u> : ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

### ២-ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាសម័យអន្តរកាល :

<u>មាត្រា៣២</u> : ជនណាដែលសម្លាប់មនុស្សដោយចេតនា ដោយបានប្រើឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋ ពី ៨ឆ្នាំទៅ ១៥ឆ្នាំ

<u>មាត្រា៣៣</u> : ជនណាក៏ដោយ ដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត

ទោះភេទដូចគ្នាឬមិនដូចគ្នាយ៉ាងណាក៏ដោយ ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោស ដាក់ជាបទឧក្រិដ្ឋ ពី៥ឆ្នាំ ទៅ ១០ឆ្នាំ ។

មាត្រា៣៩ (អំពើប្លន់) : ការលួច ធ្វើដោយអំពើហិង្សា មានអាវុធឬឥតអាវុធ បណ្តាលឬមិនបណ្តាលឱ្យមានរបួស ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់គុក ពី ៣ឆ្នាំ ទៅ១០ឆ្នាំ ។

មាត្រា៤០ ( អំពើមនុស្សឃាតដោយអចេតនា ) : ជនណាដោយខ្វះការប្រុងប្រយត្ន័ ឬមិនបានគោរពតាមបទបញ្ជា ធ្វើឱ្យស្លាប់ជនម្នាក់ទៀតដោយអចេតនា ត្រូវមានទោសពីបទមជ្ឈឹមធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

មាត្រា៤១ ( អំពើបង្ករបួសដោយចេតនា ) : ជនណាវាយតប់ បណ្តាលឱ្យមានរបួសដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្នក្នុងរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ ៥ឆ្នាំ ។

-បើពិការភាពបណ្តោះអាសន្នតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី៦ខែដល់២ឆ្នាំ ។

-បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទា គឺដាក់គុកពី១ខែដល់១ឆ្នាំ ។

-បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ ក៏រិតទោសត្រូវទ្វេមួយជាពីរ ។

**៣-ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ អំពើលក់ដូរនិងអំពើអាជីវកម្មលើមនុស្ស**

មាត្រា៣ : ជនណាអូសទាញមនុស្ស ទោះស្រីឬប្រុស អនីតិជនឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោម សន្យាឱ្យប្រាក់កាស់ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះសាមីខ្លួនសុខចិត្ត ឬមិនសុខចិត្តដោយវិធីបង្ខិតបង្ខំគំរាមកំហែង ឬប្រើថ្នាំសណ្តំស្មារតីនិងសតិអារម្មណ៍ ដើម្បីពង្រត់យកមកលក់ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំដល់១៥ឆ្នាំ ។

**ចប់**

# ប្រភេទនៃករណីរំលោភសិទ្ធិមនុស្ស

| ល.រ | ប្រភេទនៃការរំលោភ | ទីកន្លែង(ភូមិ,ឃុំ,ស្រុក) | វិធីដោះស្រាយ | សរុបករណី |
|---|---|---|---|---|
| ១ | ...........................<br>...........................<br>...................... | ......................... | ...........................<br>.......................<br>...........................<br>............................<br>..............................<br>.................................. | ............. |
| ២ | ............................<br>........................... | ............................<br>........................ | ...............................<br>...............................<br>..................................<br>..............................<br>..............................<br>.................................. | ........... |
| ៣ | ............................<br>.............................. | ..............................<br>............................. | ................................<br>..................................<br>.................................<br>..................................<br>..................................<br>...............................<br>.................................<br>..............................<br>............................. | ............ |

## ទម្រង់រាយការណ៍សង្ខេប

>>>>※<<<<

១. ឈ្មោះករណីរំលោភ :.................................................................................................

២. ជនរងគ្រោះ :

.ឈ្មោះ ...................ភេទ.................អាយុ............ មុខរបរ...............

.ទីលំនៅ : ភូមិ..................ឃុំ......................ស្រុក............ខេត្ត...............

.ទីកន្លែងកើតហេតុ : ភូមិ.............ឃុំ...............ស្រុក............ខេត្ត...............

.ពេលវេលា : ម៉ោង...............ថ្ងៃទី.........ខែ.............ឆ្នាំ២០០..

៣.អ្នករំលោភសិទ្ធិមនុស្សរបស់ជនរងគ្រោះ

.ឈ្មោះ .....................ភេទ................អាយុ..............មុខរបរ.................

.ទីលំនៅ : ភូមិ.............ឃុំ...............ស្រុក................ខេត្ត.................

.ទីកន្លែងកើតហេតុ : ភូមិ............ឃុំ.................ស្រុក...............ខេត្ត..........

.ពេលវេលា : ម៉ោង..........ថ្ងៃទី.........ខែ............ឆ្នាំ២០០..

៤.វត្ថុតាង ឬឧបករណ៍ ដែលបានរំលោភទៅលើជនរងគ្រោះ

...................................................................................................

...................................................................................................

ធ្វើនៅថ្ងៃទី ខែ ឆ្នាំ២០០..

អ្នករាយការណ៍

ហត្ថលេខា..................

ឈ្មោះ..................


សហការជាមួយ
សង្គមស៊ីវិល
ផ្តល់ពត៌មាន
ចងសម្ព័ន្ធនឹងគ្នា
ជួយបន្តការអប់រំ
សិទ្ធិមនុស្ស
យុទ្ធសាស្ត្រការពារ
សិទ្ធិមនុស្ស
សិទ្ធិមនុស្ស
ក្នុងការចូលរួម
ព្យាយាមដោះស្រាយករណីរំលោភសិទ្ធិមនុស្ស
ដោយ យុត្តិធម៌ និងអព្យាក្រិត្យ

តើរឿងក្តីនេះមានរយៈពេលប៉ុន្មានឆ្នាំ ? តើពូសាយនិងពូប្រុកលក់អស់អ្វីខ្លះ ? អ្នកណាអស់ច្រើនជាង ? តើអ្នកទាំងពីរអាចរាប់អានគ្នាបានតទៅទៀតទេ ? ហេតុអ្វី ?

២.យោងតាមដំណើររឿងនេះ បើសិនជាលោកអ្នកវិញ តើលោកអ្នកមានវិធីដោះស្រាយដូចម្តេច ? ចូរបង្ហាញវិធីដោះស្រាយទាំងនោះ ?

៣.តើលោកអ្នកមានអនុសាសន៍អ្វីបន្ថែម ក្នុងការដោះស្រាយវិវាទមួយ រវាងភាគីទាំងឡាយ ហើយដែលដំណោះស្រាយទាំងនោះ អាចធ្វើឱ្យភាគីទាំងឡាយមិនសូវខាតបង់ពេលវេលា , ប្រាក់កាស និងអាចរក្សា នូវការមិនចងកំហឹងនឹងគ្នានោះ ?

## III.សំណួរពិភាក្សាបញ្ចប់

ចូរផ្តល់យោបល់ទៅលើវិធីដោះស្រាយទាំងពីរគឺ : ការដោះស្រាយតាមផ្លូវតុលាការ និងក្រៅផ្លូវតុលាការ តើវិធីមួយណា ប្រសើរជាងវិធីមួយណា ?

## IV.ឧបសម្ព័ន្ធ

**១.វិធីសាស្ត្រសំខាន់ៗសំរាប់ដោះស្រាយវិវាទទ្វេបថ** (ដោះស្រាយក្រៅផ្លូវតុលាការ)

⁕ មានវិធីសំខាន់បី ដែលត្រូវបានគេប្រើជាញឹកញាប់ :

**១ក-ការចរចា** : មានន័យថា ភាគីទំនាស់ដោះស្រាយការវិវាទដោយផ្ទាល់រវាងពួកគេខ្លួនឯង ឬក៏អាចមានជំនួយពីអ្នកដទៃ ក្នុងការសំរុះសំរួលគ្នា ។ ម៉្យាងទៀតក៏គេធ្លាប់ប្រើសាមញ្ញថា "ខុសត្រូវអីនិយាយគ្នាឱ្យហើយ " ឬ តថ្លៃគ្នាឱ្យហើយ ចៀសវាងការប៉ះទង្គិចធំដុំ ។ វិធីចរចាគ្នា ផ្តល់នូវគុណសម្បត្តិច្រើនសំរាប់ដោះស្រាយវិវាទ ដូចជា :

1-មិនសូវមានចំណាយលុយកាក់ : ( មិនប្រើប្រាស់ភាគីទី៣)

2-មិនផ្លូវការ ( ក្រៅផ្លូវការ) : វាគ្រាន់តែរវាងភាគីទាំងឡាយឬតំណាងរបស់គេ

3-ការដោះស្រាយដោយភាគី : ដោយសារភាគីទាំងឡាយព្យាយាមសំរេចដំណោះស្រាយមួយដោយផ្ទាល់ខ្លួន ។

4-មិនសូវប្រឈមមុខដាក់គ្នា : អាចរក្សាការទំនាក់ទំនងរវាងគ្នានឹងគ្នាជាបន្តទៅទៀត

5-ភាពជាឯកជន : ការចរចាពាក់ពន្ធ័តែភាគីទាំងឡាយ ឬតំណាងរបស់គេតែប៉ណ្ណោះ ក៏ប៉ុន្តែវិធីចរចាគ្នាក៏មានគុណវិបត្តិខ្លះដែរ ដូចជា :

1-ការពន្យាពេល : បានន័យថា ភាគីម្ខាងទៀតអាចប្រើការចរចាជាល្បិចពន្យាពេល ដើម្បីបន្ថយការទប់ទល់របស់ភាគីម្ខាងទៀត ឬរារាំងភាគីម្ខាងទៀតពីការដាក់ពាក្យបណ្តឹង ។

2-ការប្រតិបត្តិការដោះស្រាយ : ប្រសិនបើភាគីទាំងឡាយ ចរចារកការដោះស្រាយ មិនមានការធានាថាភាគីមួយបំពេញកាតព្វកិច្ចរបស់ខ្លួននោះទេ ។

**១៩-ការសំរុះសំរួល ឬ ផ្សះផ្សា** : គឺជាដំណើរការមួយដែលអ្នកទី៣ ត្រូវបានជ្រើសរើសឡើងដោយស្ម័គ្រចិត្តពីភាគីទាំងឡាយ ដែលមានវិវាទជាមួយគ្នាទៅវិញទៅមក ។ នៅក្នុងការផ្សះផ្សាភាគីទី៣ ឬហៅថាអ្នកសម្រុះសម្រួល (សន្ធានការី) ត្រូវមានភាពអព្យាក្រិត្យ និងមានការគោរពទុកចិត្តពីភាគីទាំងពីរ ដើម្បីជួយដោះស្រាយវិវាទរបស់ពួកគេឱ្យបានស្រុះស្រួលនឹងគ្នា ។ អ្នកដែលអាចធ្វើជាអ្នកសំរបសំរួលបានដូចជា មន្ត្រីរដ្ឋាភិបាល , ជាសមាជិកសហគមន៍ ដែលត្រូវបានគេគោរព អ្នកដឹកនាំមូលដ្ឋាន (ប្រធានក្រុម.ប្រធានភូមិ.មេឃុំ/ចៅសង្កាត់.ព្រឹទ្ធាចារ្យ...) អ្នកដឹកនាំសាសនា ពាណិជ្ជករ មេធាវី សមាជិកសភាពាណិជ្ជកម្ម....... ក្រៅពីនេះក៏មានអង្គការមួយចំនួនជួយដោះស្រាយវិវាទ ទ្វេបថ ដោយមិនគិតកំរៃពីគូវិវាទផងដែរ ។

តួនាទីរបស់អ្នកសំរបសំរួលការវិវាទ មិនមានអំណាចដាក់បង្ខំដំណោះស្រាយណាមួយទៅលើភាគីណាមួយបានទេ ផ្ទុយទៅវិញអ្នកសំរបសំរួល ជួយភាគីទាំងឡាយនោះ ដើម្បីបង្កើតស្ថានភាពធ្វើឱ្យភាគីទាំងនោះអាចរក្សាការទំនាក់ទំនងនឹងគ្នាបានតទៅទៀត ។

*** គុណសម្បត្តិនៃការសម្រុះសម្រួល**

⋆ មិនចំណាយលុយកាក់ច្រើន : អ្នកសម្រុះសម្រួលឬសន្ធានការីតែងតែស្ម័គ្រចិត្តផ្តល់សេវារបស់គេ ឬយកថ្លៃតិចតួចតែប៉ុណ្ណោះ ។

⋆ ក្រៅផ្លូវការ : មិនមានវិធាន ឬ សវនាការជាផ្លូវការទេ ទោះបីអង្គការសំរុះសំរួលអាចមាននីតិវិធីដែលភាគីទាំងឡាយត្រូវតែធ្វើតាមក៏ដោយ ។

★ការដោះស្រាយដោយភាគីទាំងឡាយ ៖ ដ អ្នកសម្រុះសម្រួលគ្រាន់តែជួយភាគីទាំងឡាយដើម្បីរកដំណោះស្រាយ ។

★ប្រតិបក្ខតិចតួច ៖ ការសំរុះសំរួលផ្អែកទៅលើសហប្រតិបត្តិការ និងការដោះស្រាយបញ្ហាទៅវិញទៅមក ដោយផ្អែកទៅលើផលប្រយោជន៍របស់ភាគីទាំងឡាយ ។

★ភាពឯកជន ៖ អ្នកសម្រុះសម្រួលត្រូវបានតម្រូវឱ្យរក្សាព័ត៌មានដែលបានដឹងពីភាគីទាំងឡាយជាសម្ងាត់ ។

★រក្សាទំនាក់ទំនង ៖ ភាគីទាំងឡាយរៀនយល់គ្នាទៅវិញទៅមក និងធ្វើឱ្យទំនាក់ទំនងរបស់គេត្រឹមត្រូវឡើង ។

**★គុណវិបត្តិនៃការសំរុះសំរួល**

★ពន្យាពេល ៖ ភាគីម្ខាងអាចស្នើរកការសម្រុះសម្រួល ជាវិធីមួយដើម្បីពន្យាពេលធ្វើឱ្យភាគីម្ខាងទៀតចាប់ផ្តើមដាក់បណ្តឹងវិវាទ ។

★លក្ខណៈស្ម័គ្រចិត្ត ៖ ភាគីទាំងពីរត្រូវតែមានបំណងនិងព្រមព្រៀងសំរុះសំរួលដោយស្ម័គ្រចិត្ត ។

★ការប្រតិបត្តិដំណោះស្រាយ ៖ ប្រសិនបើភាគីមិនបំពេញកាតព្វកិច្ចរបស់ខ្លួនតាមការដោះស្រាយសម្រុះសម្រួលទេនោះ ភាគីម្ខាងទៀតនៅតែអាចធ្វើសាទុក្ខការត្រឡប់បាន ។

**១៣-មជ្ឈត្តការ** ((ការវិនិច្ឆ័យដោយអាជ្ញាកណ្តាល)

មជ្ឈត្តការ គឺជាវិធីមួយនៃការដោះស្រាយវិវាទឯកជន ដែលមានភាគីអព្យាក្រឹត្យទី៣ ហៅថា មជ្ឈត្តការ ឬ គណៈកម្មមជ្ឈត្តការ ស្តាប់វិវាទរបស់ភាគីទាំងឡាយ ពិនិត្យមើលភស្តុតាង និងចេញសេចក្តីសំរេចដែលគេហៅថាការវិនិច្ឆ័យដើម្បីដោះស្រាយវិវាទ ។

មជ្ឈត្តការ បើប្រៀបធៀបទៅនឹងបណ្តឹងវិវាទ គេគិតថាមជ្ឈត្តការជាការកាត់សេចក្តីលើវិវាទឯកជន រីឯតួនាទីរបស់មជ្ឈត្តការគឺជាតួនាទីឯកជន ក៏ប៉ុន្តែប្រហាក់ប្រហែលទៅនឹងតួនាទីរបស់ចៅក្រមសាធារណៈដែរ។ តួនាទីរបស់មជ្ឈត្តការនឹងដោះស្រាយកំណត់ " អ្នកណាត្រូវ " ដូចជាការកាត់ក្តីជាសាធារណៈដែរ ក៏ប៉ុន្តែការខុសគ្នាគឺនៅក្នុងមជ្ឈត្តការ ភាគីទាំងឡាយត្រូវបានផ្តល់

ភាគីមួយអាចព្យាយាមពន្យាពេល ឬរារាំងមជ្ឈត្តការ ដោយអះអាងថាវិវាទនេះក្រៅពីទំហំនៃ ខ្សែងពី មជ្ឈត្តការ ។

## V.សេចក្តីព្រាងច្បាប់ស្តីពីមជ្ឈត្តការនៅកម្ពុជា :

បច្ចុប្បន្នរដ្ឋាភិបាលកម្ពុជាកំពុងពិចារណាសេចក្តីព្រាងច្បាប់ស្តីពីមជ្ឈត្តការ ។ ច្បាប់នេះនឹងអាចធ្វើឱ្យតុលាការកម្ពុជាទទួលស្គាល់ ។

សេចក្តីព្រាងច្បាប់នេះ អាចអនុវត្តទៅលើមជ្ឈត្តការទាំងក្នុងស្រុក និងអន្តរជាតិផងដែរ ។

## VI.សន្និដ្ឋាន :

ការប្រៀបធៀបអំពីដំណោះស្រាយក្នុងប្រពន្ធ័ (តាមផ្លូវតុលាការ) និងក្រៅប្រព័ន្ធ (ក្រៅផ្លូវតុលាការ) ដែលបានរៀបរាប់ខាងលើនេះ គឺមានគោលបំណងឱ្យបុគ្គលម្នាក់ៗរួមទាំងនគរបាលផង បានស្វែងយល់អំពីវិវាទនានាដែលបានកើតឡើង ទោះផ្ទាល់ខ្លួនក្តី ចំពោះអ្នកដទៃក្តី ថាតើវិវាទណាដែលត្រូវដោះស្រាយតាមផ្លូវតុលាការ និងវិវាទណាដែលគួរដោះស្រាយក្រៅផ្លូវតុលាការ ។

ដូចអស់លោកនគរបាលជាតិបានជ្រាបហើយថា ចំពោះរឿងក្តីព្រហ្មទណ្ឌ ឬក៏បណ្តឹងអាជ្ញា គឺមិនអាចសំរុះសំរួលបានឡើយក្រៅពីតុលាការ ក៏ប៉ុន្តែការកើតវិវាទបែបរដ្ឋប្បវេណី គឺជាការសំរេចចិត្តផ្ទាល់របស់សាមីរួមទាំងនគរបាលផង ថាតើគេចង់ដោះស្រាយតាមប្រពន្ធ័ណាមួយ ក្នុងចំណោមទាំងពីរខាងលើនេះ ដើម្បីភាពយុត្តិធម៌សំរាប់ខ្លួនគេ ។ បើគេចង់ដោះស្រាយជាឯកជន គេអាចជ្រើសរើសតាមវិធីចរចារវាងភាគីវិវាទរបស់គេ ឬតាមវិធីសំរុះសំរួល ដោយជ្រើសរើសអ្នកទីពាណាមួយដែលគេពេញចិត្ត គឺមិនមាននរណាមួយ រារាំង ញុះញង់ ឬប្រើល្បិចកលដើម្បីជំរិតយកផលប្រយោជន៍សំរាប់ផ្ទាល់ខ្លួននោះឡើយ ។

ដូច្នេះនគរបាលក៏អាចជួយអប់រំប្រជាពលរដ្ឋឱ្យមានសន្តិភាពបានដែរ ដូចជាជួយបង្ការ និង ទប់ស្កាត់នូវរាល់ទំនាស់ដែលប្រុងនឹងកើតឡើងបែបហិង្សា ក៏ប៉ុន្តែនគរបាលមិនអាចឆ្លៀតឱកាសគំរាម ឬ បំភិតបំភ័យ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនណាមួយនោះឡើយ ។

**ចប់**

**សម្ព័ន្ធខ្មែរ ជំរឿននិង ការពារសិទ្ធិមនុស្ស ដែលហៅកាត់ថា លីកាដូ**

គឺជាសមាគមដែលមិនមែនរដ្ឋាភិបាល មិនរកផលកំរៃ ហើយមិនមែនជាគណៈបក្សនយោបាយឡើយ ។

សមាគមនេះមានគោលដៅបង្រៀន និងផ្សព្វផ្សាយអំពិសិទ្ធិមនុស្ស ព្រមទាំងការពារប្រជាពលរដ្ឋនូវអំពើរំលោភសិទ្ធិមនុស្ស ។

ចំណែកពត៌មានផ្សេងៗ សូមអញ្ជើញមកទាក់ទងនៅការិយាល័យលីកាដូ ស្ថិតនៅផ្ទះលេខ ១០៣ ផ្លូវ៩៧ ខណ្ឌចំការមន ក្រុងភ្នំពេញ ។


**នាយិកាប្រតិបត្តិ លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវ កេក**

សូមទំនាក់ទំនង ទូរស័ព្ទលេខ: ( ០២៣) ៣៦០៩៦៥/២១១៣៩១

ទូរសារលេខ: ( ០២៣) ៣៦០៩៦៥/២១៧៦២៦

អ៊ីមែល: licadho@camnet.com.kh


The Cambodian League for Promotion and Defense of Human Rights is a non governmental non profit , non political organization , whose objectives is to teach Human Rights and Protect the population from Human Rights violations.

For further information please contact LICADHO #103.St.97, Khan ChamcarMon , Phnom-Penh.


Executive director : Dr. Pung Chhiv Kek
Phone : (023)360965/211391
fax : (023)360965/217/626
E-mail : licadho@camnet.com.kh.

# ហាមលក់
# NOT FOR SALE

បោះពុម្ពផ្សាយ និង គាំទ្រដោយ
អំណោយថវិការបស់ NORAD

Publish with a grant
from NORAD

រក្សាសិទ្ធិ **លីកាដូ** ឆ្នាំ២០០២
Copyright 2002 LICADHO

**លីកាដូ**

**LICADHO**

បោះពុម្ពលើកទី ២ ដោយ

**អង្គការសម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស**

**First Edition**

បោះពុម្ពលើកទី២ ៥០០ ក្បាល
ខែ ឧសភា ឆ្នាំ ២០០៣